ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី

រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០០៩

លេខ : ០៥៧ មស.សក

**រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

**សូមគោរពជូន**

**ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ**

**គ្រប់ក្រសួង-ស្ថាប័ន**

**កម្មវត្ថុ** :-ការណែនាំបន្ថែមនូវនីតិវិធីក្នុងការដំឡើងថ្នាក់ ការតាំងស៊ប់មន្ត្រីរាជការក្របខ័ណ្ឌថ្មី និងការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍តាមគោលការណ៍ ។

**យោង** :-ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។

-ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនានា ។

-លិខិតលេខ ៦០០ ម.ស.ន.ក ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីនីតិវិធីក្នុងការបំពេញបែបបទមួយចំនួនលើការដំឡើងថ្នាក់ជូនមន្ត្រីរាជការស៊ីវិល ។

ខ្ញុំមានកិត្តិយស សូមជម្រាបជូនឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន សូមជ្រាបថា បច្ចុប្បន្នមន្ត្រីរាជការស៊ីវិលត្រូវបានធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌថ្មី ស្របតាមខ្លឹមសារព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនានារួចហើយនោះ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សូមធ្វើការណែនាំបន្ថែម នូវនីតិវិធីមួយចំនួនពាក់ព័ន្ធនឹងមន្ត្រីរាជការស៊ីវិល មានដូចខាងក្រោម :

**១-<u>ការស្នើសុំដំឡើងថ្នាក់មន្ត្រីរាជការស៊ីវិល</u>**

**ក/<u>ការដំឡើងថ្នាក់ប្រចាំឆ្នាំ</u>**

ក្រសួង-ស្ថាប័ននីមួយៗ ត្រូវផ្ញើឯកសារស្នើសុំដំឡើងថ្នាក់ប្រចាំឆ្នាំរបស់មន្ត្រីរាជការស៊ីវិល ឱ្យបានទាន់កាលកំណត់ យ៉ាងយូរ (មុនដំណាច់ខែកុម្ភៈ សម្រាប់ឆ្នាំ២០០៩) មកឱ្យរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដើម្បីរៀបចំធ្វើសេចក្តីព្រាង ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ព្រមទាំងផ្តល់ទិដ្ឋាការដំឡើងថ្នាក់ទៅតាមលក្ខន្តិកៈដោយឡែកឱ្យបានសមស្រប និងតាមកាលបរិច្ឆេទកំណត់ គឺថ្ងៃទី ១៣ ខែ មេសា រៀងរាល់ឆ្នាំ ។ ដើម្បីជាប្រយោជន៍ដល់មន្ត្រីរាជការ ស្នើក្រសួង-ស្ថាប័ននីមួយៗ យកចិត្តទុកដាក់ក្នុងការរៀបចំសំណុំបែបបទនិងបញ្ជូនមកឱ្យបានទៀងទាត់ និងទាន់ពេលវេលា ។

**ខ/<u>ការដំឡើងថ្នាក់តាមកម្រិតសញ្ញាបត្រ</u>**

ការស្នើសុំដំឡើងថ្នាក់មន្ត្រីរាជការតាមកម្រិតសញ្ញាប័ត្រ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ នឹងពិនិត្យផ្តល់ទិដ្ឋាការជូនលើសំណើសុំរបស់ក្រសួង-ស្ថាប័ន តែពីរលើកប៉ុណ្ណោះ គឺក្នុងខែឧសភា និងខែសីហា រៀងរាល់ឆ្នាំ ។

## ២. ការតាំងស៊ប់មន្ត្រីរាជការទៅក្នុងក្របខ័ណ្ឌ តាមលក្ខន្តិកៈដោយឡែក

កន្លងមក រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ បានពិនិត្យឃើញក្រសួង-ស្ថាប័ន មួយចំនួន អនុវត្តពុំទាន់បានត្រឹមត្រូវទៅតាមខ្លឹមសារព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនានានៅឡើយ ជាពិសេសនីតិវិធីនៃការតាំងស៊ប់មន្ត្រីរាជការក្របខ័ណ្ឌថ្មីទៅក្នុងក្របខ័ណ្ឌតាមលក្ខន្តិកៈដោយឡែក ដែលក្របខ័ណ្ឌ "ក" ត្រូវតាំងស៊ប់ដោយព្រះរាជក្រឹត្យ និងក្របខ័ណ្ឌ "ខ" ត្រូវតាំងស៊ប់ដោយអនុក្រឹត្យ ដោយឡែកក្របខ័ណ្ឌ "គ" និង "ឃ" ត្រូវចេញដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈសម្រាប់តែក្របខ័ណ្ឌរដ្ឋបាលទូទៅ និងដោយប្រកាសរបស់ក្រសួង-ស្ថាប័ន គ្រប់គ្រងក្របខ័ណ្ឌសម្រាប់ក្របខ័ណ្ឌដទៃទៀត ដោយមានទិដ្ឋាការពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។ បញ្ហានេះ ក្រសួង-ស្ថាប័នមួយចំនួន នៅអនុវត្តការតាំងស៊ប់មន្ត្រីរាជការដោយប្រកាសរបស់ក្រសួង-ស្ថាប័នសាមីនៅឡើយ នាំឱ្យខុសពីនីតិវិធីនៃការតាំងស៊ប់មន្ត្រីរាជការស៊ីវិល ដែលបានចែងក្នុងខ្លឹមសារព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែក។

ផ្អែកតាមវាក្យខ័ណ្ឌខាងលើនេះ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សូមជម្រាបជូនថា ចំពោះមន្ត្រីកម្មសិក្សាការីដែលបានបញ្ចប់ពេលវេលាកម្មសិក្សា និងទទួលលទ្ធផលបានជោគជ័យ ហើយមានការវាយតម្លៃត្រឹមត្រូវពីគណៈកម្មការរួចហើយ គ្រប់ក្រសួង-ស្ថាប័នសាមី ត្រូវបញ្ជូនសំណុំលិខិតស្នើសុំតាំងស៊ប់មន្ត្រីរាជការទាំងនេះ ទៅក្នុងក្របខ័ណ្ឌតាមលក្ខន្តិកៈដោយឡែក មករដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈនៅខែបន្ទាប់ ដើម្បីរៀបចំបែបបទតាមនីតិវិធីស្តីពីការតាំងស៊ប់មន្ត្រីរាជការស៊ីវិល ដែលមានចែងក្នុងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែក ។

## ៣. ការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍

ដើម្បីឱ្យសមស្របតាមខ្លឹមសារព្រះរាជក្រម ស្តីពីច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងសារាចរលេខ ០២ សរ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ គ្រប់ក្រសួង-ស្ថាប័នសាមី ត្រូវអនុវត្តនូវនីតិវិធីក្នុងការដាក់មន្ត្រីរាជការស៊ីវិលទាំងពីរភេទឱ្យចូលនិវត្តន៍ទៅតាមគោលការណ៍ ដែលបានចែងក្នុងខ្លឹមសារព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនានា ឱ្យបានទាន់ពេលវេលា ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន មេត្តាអនុវត្តតាមខ្លឹមសារខាងលើតាមការគួរ ។

សូមឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

**ចម្លងជូន**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

"ដើម្បីជូនជ្រាប"

- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ